**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

## សារជូនពរ

**សូមគោរពជូន**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**

**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីចម្រើនជន្មាយុគម្រប់ ៨៩ ឈានចូល ៩០ ឆ្នាំ**

***សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហានទាំងអស់នៃកងយោធពលខេមរភូមិន្ទ នាឱកាសដ៏នក្ខត្តឫក្ស នៃពិធីចម្រើនជន្មាយុគម្រប់ ៨៩ ឈានចូល ៩០ ឆ្នាំ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២៣នេះ ក្នុងនាមខ្ញុំនិងភរិយា សូមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សិរីមង្គលវិបុលសុខមហាប្រសើរ ជូន **សម្តេចអគ្គមហាពញាចក្រី** សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងខ្លាំងក្លា បញ្ញាញាណវាងវៃ ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំស្ថាប័នរដ្ឋសភាឱ្យមានការរីកចម្រើនថែមទៀត។

យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវសេចក្តីគោរពដ៏ស្មោះស្ម័គ្រ និងកោតសរសើរយ៉ាងក្រៃលែងនូវការដឹកនាំរបស់ **សម្តេចអគ្គមហាពញាចក្រី** ដែលជានិច្ចកាល **សម្តេច** តែងបានខិតខំប្រឹងប្រែងយកអស់កម្លាំងកាយ និងប្រាជ្ញាស្មារតី ជាមួយនឹងបទពិសោធន៍ដ៏ប៉ិនប្រសប់ប្រកបដោយគំរូវីរភាពដ៏មោះមុតសម្រេចបាននូវស្នាដៃនិងសមិទ្ធផលជាច្រើនគួរឱ្យស្ញប់ស្ញែងជាបន្តបន្ទាប់ ជំរុញឱ្យស្ថាប័នរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលជាស្ថាប័នកំពូលរបស់ជាតិ មានការរីកចម្រើនឥតឈប់ឈរ រួមចំណែកដល់ការលើកកម្ពស់នីតិរដ្ឋ ស្របតាមបំណងប្រាថ្នាដែលប្រជាជនចង់បាន។

ជាថ្មីម្តងទៀត ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងកងយោធពលខេមរភូមិន្ទទាំងមូល ក្នុងនាមខ្ញុំនិងភរិយា សូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតាឆ្នាំថ្មី ទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរជ័យ សិរីមង្គលវិបុលសុខ ជូនចំពោះ **សម្តេចអគ្គមហាពញាចក្រី** និង**សម្តេចធម្មវទ្ធនសុទ្ធចរិយា** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រីជាទីស្រឡាញ់ សូមបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃសុក្រ ៧កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា **ទៀ បាញ់**